# មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព

ព្រឹត្តិបត្រព័ត៌មាន លេខទី ៦ | កក្កដា-កញ្ញា ២០២២

- ការលើកកម្ពស់សុខភាព មាតា ទារកនិងកុមារ
- ផ្សេងៗស្តីពីការផ្លាស់ប្តូរឥរិយាបថនិងការលើកកម្ពស់សុខភាព



## ការលើកកម្ពស់សុខភាព មាតា ទារកនិងកុមារ

ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សុខភាព មាតា ទារកនិងកុមារ ដោយក្នុងនោះរួមមាន ការកាត់បន្ថយអត្រាមរណភាពរបស់មាតា ទារកនិងកុមារ ឱ្យធ្លាក់ចុះមកនៅកម្រិតទាបបំផុត ។ ជាក់ស្តែង យោងតាមលទ្ធផលបឋមនៃការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ២០២១-២០២២ អត្រាមរណភាពមាតា ទារកនិងកុមារ បានធ្លាក់ចុះបើប្រៀបធៀបរវាងឆ្នាំ ២០១៤ និងឆ្នាំ ២០២១-២០២២ ។ ក្នុងនោះរួមមាន :

- អត្រាមរណភាពមាតាបានថយចុះពី ១៧០ នាក់ នៅឆ្នាំ ២០១៤ មកនៅ ១៥៤ នាក់ ក្នុងទារកកើតរស់ ១០០,០០០ នាក់ នៅឆ្នាំ ២០២១-២០២២ ។
- អត្រាមរណភាពទារកបានថយចុះពី ១៨ នាក់ នៅឆ្នាំ ២០១៤ មកនៅ ៨ នាក់ ក្នុងទារកកើតរស់ ១,០០០ នាក់ នៅឆ្នាំ ២០២១-២០២២ ។
- អត្រាមរណភាពកុមារអាយុក្រោម ១ ឆ្នាំបានថយចុះពី ២៨ នាក់ នៅឆ្នាំ ២០១៤ មកនៅ ១២ នាក់ ក្នុងទារកកើតរស់ ១,០០០ នាក់ នៅឆ្នាំ ២០២១-២០២២ ។
- អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំបានថយចុះពី ៣៥ នាក់ នៅឆ្នាំ២០១៤ មកនៅ ១៦ នាក់ ក្នុងទារកកើតរស់ ១,០០០ នាក់ នៅឆ្នាំ ២០២១-២០២២ ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅមានឧបសគ្គខ្លះទៀតដែលយើងទាំងអស់គ្នាត្រូវខិតខំធ្វើការងារ

បន្ថែមទៀត ដើម្បីធ្វើយ៉ាងណាឱ្យស្ត្រីនិងកូនៗចាកឆ្ងាយពីជំងឺផ្សេងៗ ជាពិសេសគឺឱ្យពួកគាត់ទទួលបាននូវសេវាសុខភាពដែលមានគុណភាពនិងយល់ដឹងអំពីអាហារូបត្ថម្ភ ។

កង្វះអាហារូបត្ថម្ភគឺជាបញ្ហាអាទិភាពមួយដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងយកចិត្តទុកដាក់ក្នុងការដោះស្រាយនិងធ្វើឱ្យបានប្រសើរឡើង ដើម្បីឈានទៅរកការកាត់បន្ថយអត្រាស្លាប់របស់មាតា ទារកនិងកុមារ ជាពិសេសក្នុងចំណោមក្រុមប្រជាជនងាយរងគ្រោះនៅតាមមូលដ្ឋាន ។

រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា កុមារដែលមានសុខភាពនិងអាហារូបត្ថម្ភនឹងធ្វើឱ្យពួកគាត់មានភាពឆ្លាតវៃ ហើយមានសុខភាពល្អតាំងពី ១០០០ ថ្ងៃដំបូងនៃជីវិត ដែលជាទុនមួយអាចជួយឱ្យកុមារសម្រេចបាននូវឱកាសដ៏មានសក្ដានុពលរបស់ខ្លួនក្នុងការសិក្សា ការច្នៃប្រឌិត, និងការរកប្រាក់ចំណូលនៅពេលពួកគេធំពេញវ័យ ។





ក្នុងសារលិខិតរបស់**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន**ប្រធានកាកបាទក្រហមកម្ពុជា ក្នុងឱកាសទិវាជាតិសុខភាពមាតា ទារកនិងកុមារ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២២ ក្រោមប្រធានបទ " ពង្រឹងការផ្ដល់សេវាសុខភាពបន្តពូជ សុខភាពមាតា ទារកនិងកុមារ និងការផ្ដល់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនស្ត្រីមានផ្ទៃពោះនិងមាតាកំពុងបំបៅកូនដោយទឹកដោះម្ដាយ " សម្ដេចបានអំពាវនាវដល់គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ទាំងជាតិនិងអន្តរជាតិ សូមបន្តជួយវិនិយោគ គាំទ្រដល់ការងារសុខភាពមាតា ទារកនិងកុមារ ពិសេសជួយលើការងារបណ្ដុះបណ្ដាលនិងវិក្រឹត្យការ ដល់មន្ត្រីនិងបុគ្គលិកសុខាភិបាល អាជ្ញាធរមូលដ្ឋាន អ្នកអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ ឱ្យទទួលបានចំណេះដឹងនិងជំនាញពិតប្រាកដ ដើម្បីពង្រឹងគុណភាព និងគុណតម្លៃនៃការផ្ដល់សេវាសុខភាពបន្តពូជ មាតា ទារកនិងកុមារ, និងផ្ដល់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនស្ត្រីមានផ្ទៃពោះនិងមាតាកំពុងបំបៅទឹកដោះម្ដាយ ។

ដើម្បីកាត់បន្ថយអត្រាមរណភាពទារកទើបនឹងកើត និងធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភរបស់មាតា ទារកនិងកុមារ ក្រសួងសុខាភិបាលកំពុងអនុវត្តគម្រោងមួយដែលមានឈ្មោះថា គម្រោងអាហារូបត្ថម្ភនៅកម្ពុជា ដែលមានតំបន់គោលដៅនៅក្នុងខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តកំពង់ឆ្នាំងនិងខេត្តកោះកុង ។





នៅក្នុងគម្រោងអាហារូបត្ថម្ភនៅកម្ពុជា មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព មានតួនាទីសំខាន់មួយក្នុងការកសាងនិងបង្កើនសមត្ថភាពដល់ក្រុមទ្រទ្រង់សុខភាពភូមិ ដែលជាអ្នកអប់រំផ្សព្វផ្សាយនៅតាមសហគមន៍ដ៏សំខាន់ ។

មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពបានបង្កើតឱ្យមានវគ្គបណ្តុះបណ្តាលដល់ពួកគេ ដើម្បី :

- បង្កើនចំណេះដឹងអាហារូបត្ថម្ភ នៅក្នុងពេល ១០០០ ថ្ងៃដំបូងនៃជីវិត ជំនាញ និងតួនាទីរបស់ក្រុមទ្រទ្រង់សុខភាពភូមិក្នុងការអនុវត្តកម្មវិធីឃុំ សង្កាត់សម្រាប់ស្ត្រីនិងកុមារ ប្រកបដោយជោគជ័យ
- រៀបរាប់អំពីទិដ្ឋភាពទូទៅនៃកម្មវិធីឃុំ សង្កាត់សម្រាប់ស្ត្រីនិងកុមារ
- បង្កើនចំណេះដឹងនិងជំនាញក្នុងការគូសផែនទីសង្គមនិងការប្រាស្រ័យទាក់ទងអន្តរបុគ្គលដើម្បីផ្លាស់ប្តូរឥរិយាបថក្នុងការក្នុងការអនុវត្តកម្មវិធីឃុំ សង្កាត់ សម្រាប់ស្ត្រីនិងកុមារ
- ទទួលបានចំណេះដឹងនិងជំនាញអំពីសុខភាពមាតា ទារក កុមារនិងអាហារូបត្ថម្ភ
- បង្កើនចំណេះដឹងពីការចុះផ្តល់សេវាសុខភាពមូលដ្ឋាននិងការលើកកម្ពស់មូលនិធិសមធម៌ ។

វគ្គបណ្តុះបណ្តាលនេះត្រូវបានបង្កើតឡើងដោយក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានារួមមានមជ្ឈមណ្ឌលជាតិគាំពារមាតា ទារក និង



កុមារ កម្មវិធីជាតិអាហារូបត្ថម្ភនៅកម្ពុជា ទីភ្នាក់ងារបញ្ជាក់ចំណាយ នាយកដ្ឋានការពារសុខភាព នាយកដ្ឋានផែនការនិងព័ត៌មាននៃក្រសួងសុខាភិបាល និងលេខាធិការដ្ឋាន គ.ជ.អ.ប អ្នកពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិ, និងបុគ្គលិកបច្ចេកទេសនៃធនាគារពិភពលោក ។

តាមរយៈវគ្គបណ្តុះបណ្តាលនេះ មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព បានរួមចំណែកលើកកម្ពស់ការអនុវត្តកម្មវិធីឃុំ សង្កាត់ សម្រាប់ស្ត្រីនិងកុមារឱ្យកាន់តែមានប្រសិទ្ធភាព, និងឆ្លើយតបតម្រូវការនៅតាមមូលដ្ឋានឱ្យបានទាន់ពេលវេលា ។

ក្រៅពីការបណ្តុះបណ្តាលក្រុមទ្រទ្រង់សុខភាពភូមិនៅក្នុងគម្រោងអាហារូបត្ថម្ភនៅកម្ពុជា មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពក៏ផលិតសម្ភារអប់រំសុខភាពស្តីពីជំងឺកូវីដ-១៩ សម្រាប់ស្ត្រីមានផ្ទៃពោះផងដែរ ដោយសារស្ត្រីមានផ្ទៃពោះស្ថិតនៅក្នុងក្រុមប្រឈមជាមួយជំងឺកូវីដ-១៩ ។ សម្ភារអប់រំទាំងនោះ

មានគោលបំណងជំរុញឱ្យស្ត្រីមានផ្ទៃពោះនិងកុមារដែលគ្រប់អាយុឱ្យទៅចាក់វ៉ាក់សាំង ។ សម្ភារអប់រំទាំងនោះរួមមាន ផ្ទាំងរូបភាព, និងវីដេអូ ត្រូវបានផ្សព្វផ្សាយនៅតាមបណ្តាញសង្គម ទូរទស្សន៍ វិទ្យុ និងនៅតាមមណ្ឌលសុខភាព ។

ការចាក់វ៉ាក់សាំងដូសមូលដ្ឋាននិងដូសជំរុញពិតជាមានសារៈសំខាន់ណាស់សម្រាប់ស្ត្រីមានផ្ទៃពោះ ដោយវាបានជួយបង្កើនប្រព័ន្ធការពាររបស់ស្ត្រីឱ្យមានភាពរឹងមាំ ទប់ស្កាត់នឹងវីរុសកូវីដ-១៩ រួមទាំងវីរុសកូវីដ-១៩ បំប្លែងថ្មី " អូមីក្រុង " និងអាចកាត់បន្ថយការចូលសម្រាកពេទ្យ ការស្លាប់បាត់បង់ជីវិត ឬកូនកើតមិនគ្រប់ខែ ។

នៅក្នុងពិធីបិទយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី ១ ជូនមនុស្សពេញវ័យដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ នៅមន្ទីរពេទ្យជ័យជំនះស្ថិតក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០២១, **លោកជំទាវ ឱ វណ្ណឌីន** រដ្ឋលេខាធិការក្រសួងសុខាភិបាលនិងជាប្រធានគណៈកម្មការចំពោះ-




កិច្ចចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បានបញ្ជាក់ថា ៖ " ចំពោះស្ត្រីមានផ្ទៃពោះ ឬបំបៅកូនដោយទឹកដោះនេះ ប្រសិនបើគាត់មានសុខភាពធម្មតា គាត់អត់មានជំងឺតម្កាត់អីទេ ហើយគាត់ស្ម័គ្រចិត្តចង់ចាក់ គឺគាត់អាចទៅទទួលការចាក់វ៉ាក់សាំងនេះបាន មិនថាពេលណា មិនថាខែណានោះទេ ឱ្យតែគាត់ស្រួលខ្លួន ហើយគាត់ចង់ចាក់ សូមអញ្ជើញមកចាក់ ! " ៕

## ផ្សេងៗស្តីពីការផ្លាស់ប្តូរឥរិយាបថនិងការលើកកម្ពស់សុខភាព

១) ព្រឹត្តិបត្រព័ត៌មានរបស់មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព (លេខទី ៥ | មេសា-មិថុនា ២០២២)

២) បច្ចុប្បន្នភាពយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ, និងសិទ្ធិ ២០១៧-២០២៣

៣) អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ២០២១-២០២២

៤) វីដេអូ : ស្ត្រីមានផ្ទៃពោះមានសុវត្ថិភាពក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩ (១)

៥) វីដេអូ : ស្ត្រីមានផ្ទៃពោះមានសុវត្ថិភាពក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩ (២)